CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ ២០០៩ លេខ ០៣

## ការកសាងប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ - ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រៈ កសិកម្ម និងការអភិវឌ្ឍជនបទ[1]

"វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកាត់បន្ថយតម្រូវការ និងថ្លៃទំនិញកសិកម្ម... ការធ្លាក់ថ្លៃនៃទំនិញកសិកម្ម បានរុញច្រានកសិករ និងវិនិយោគិន ឱ្យជាប់ផុងក្នុងបំណុល។"

*ប្រសាសន៍របស់ បណ្ឌិត ថេង វុទ្ធី អ្នកសំរបសំរួលកម្មវិធីនៃ CDRI*
*នៅក្នុងសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

### វិបត្តិ និងវិស័យកសិកម្មកម្ពុជាៈ ផលប៉ះពាល់ និងការខ្វះចន្លោះ

នៅកម្ពុជា វិស័យកសិកម្ម មានតួនាទីសំខាន់ជាងគេក្នុងការផ្តល់ឱកាសការងារ បើធៀបនឹងវិស័យ ឧស្សាហកម្ម និងសេវាកម្ម ប៉ុន្តែនៅទសវត្សរ៍ចុងក្រោយនេះ វិស័យកសិកម្ម ចូលរួមចំណែក ដល់កំណើនសេដ្ឋកិច្ចបានតិចបំផុត និងមិនសូវទៀងទាត់ទេ ។ តាមតួលេខធនាគារពិភពលោកសំរាប់កំណើនប្រចាំឆ្នាំរបស់កម្ពុជានៅអំឡុងឆ្នាំ១៩៩៨-២០០៧ វិស័យឧស្សាហកម្ម មានចំណែក ៤,៥% និងវិស័យសេវាកម្ម មាន ៤,៨% ហើយវិស័យកសិកម្ម មានត្រឹម ២%ប៉ុណ្ណោះ ។ វិស័យឧស្សាហកម្ម កើនឡើងជាចំបង ដោយសារផ្នែកកាត់ដេរ និងសំណង់ រីឯវិស័យសេវាកម្ម កើនឡើងដោយសារ ទេសចរណ៍ ។ ចំពោះវិស័យកសិកម្ម កំណើនភាគច្រើនពឹងផ្អែកលើផលិតកម្មផលដំណាំ ជាពិសេស ស្រូវ ។

នៅឆ្នាំ២០០៧ វិស័យកសិកម្ម រួមចំណែកប្រមាណ ២៩% នៃផលិតផលក្នុងស្រុកសរុប (ផសស) របស់កម្ពុជា ធៀបនឹងវិស័យឧស្សាហកម្ម ៣០% និងវិស័យសេវាកម្ម ៤១% ។ ទាក់ទិនការងារវិញ វិស័យកសិកម្មផ្តល់បានច្រើនណាស់ដល់ ៥៩%នៃការងារសរុប ធៀបនឹងវិស័យឧស្សាហកម្ម ១៣% និងវិស័យសេវាកម្ម ២៧% ។ ប៉ុន្តែផលិតភាពពលកម្មក្នុងវិស័យកសិកម្ម មានកំរិតទាប ហើយវិនិយោគក្នុងវិស័យនេះក៏មិនទាន់គ្រប់គ្រាន់នៅឡើយ ។ ផលិតកម្មកសិកម្ម ត្រូវបានរាំងស្ទះដោយបញ្ហាទិន្នផលទាប លក្ខខណ្ឌអាកាសធាតុមិនអំណោយផល បច្ចេកទេសចាស់ហួសសម័យ និងបញ្ហាជាច្រើនទៀត ។ នៅកម្ពុជា ដោយសារប្រជាជនក្រីក្ររស់នៅផ្តុំគ្នាឯជនបទ ដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម ដូច្នេះបញ្ហាដែលជះឥទ្ធិពលដល់វិស័យនេះ ក៏ជះឥទ្ធិពលដល់ កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រដែរ ។

ជាភ័ព្វល្អសំរាប់វិស័យកសិកម្ម វិបត្តិស្បៀងពិភពលោកដែលបានផ្តើមចេញពីកំណើនថ្លៃយ៉ាងគំហុក កាលពីឆ្នាំ២០០៦ បានជួយផលិតកម្មកសិកម្មឲ្យរស់រវើកឡើងវិញ ហើយជាលទ្ធផល ប្រជាកសិករសង្ឃឹមថានឹងទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ ។ ប៉ុន្តែវិបត្តិសេដ្ឋកិច្ចនៅពេលបច្ចុប្បន្ន បានគំរាមកំហែងដល់ក្តីសង្ឃឹមដែលប្រជាកសិករទន្ទឹងរង់ចាំជាយូរមកហើយ ។

ពីឆ្នាំ២០០៦ ដល់ពាក់កណ្តាលឆ្នាំ២០០៨ ថ្លៃម្ហូបអាហារពិភពលោកបានស្ទុះឡើង ដោយសារមូលហេតុមួយចំនួន ដូចជា ការប្រមូលផលបានតិច ថាមពលឡើងថ្លៃខ្ពស់ អាកាសធាតុមិនអំណោយផល និងកំណើនការប្រកួតប្រជែងរវាងផលិតកម្មជីវឥន្ធនៈ និងស្បៀង ។ ថ្លៃម្ហូបអាហារខ្ពស់បានគំរាមកំហែងដល់សន្តិសុខស្បៀងរបស់ប្រជាជនជាច្រើននៅលើសាកលលោក ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ វាក៏ជាដំណឹងល្អសំរាប់កសិករ និងអ្នកនាំចេញផលិតផលកសិកម្មដែរ ។ ក្នុងឆ្នាំ២០០៧ ផលិតផលកសិកម្មនាំចេញសំខាន់ៗ ដូចជា ស្រូវ ដំឡូងឈើ និងកៅស៊ូ ក្នុងមួយតោនឡើងថ្លៃដល់ ២២៥ដុល្លារ ៧០ដុល្លារ និង ២០១៦ដុល្លារ ដែលបានជំរុញ

[1] អត្ថបទនេះ ជាការបូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗក្នុងវគ្គទី៣ក(១) នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។ វាគ្មិនក្នុងវគ្គនេះមានដូចតទៅ: ឯកឧត្តម ណាំ ទុំ ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងជាអភិបាលខេត្តកំពង់ធំ និង បណ្ឌិត ថេង វុទ្ធី អ្នកសំរបសំរួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃ *CDRI* ។

**ក្រាហ្វិក ១: កំណើនផលិតកម្មនៅរវាងឆ្នាំ២០០៧_០៨ គិតជា ពាន់តោន**




*ប្រភព: ស្ថិតិកសិកម្ម ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ឲ្យមានការបង្កើនផលិតកម្ម និងការនាំចេញ ។ ផលិតកម្មដំឡូងឈើកើនពី ២,២លានតោនក្នុងឆ្នាំ២០០៧ ដល់ ៣,៤លានតោនក្នុងឆ្នាំ២០០៨ ហើយផលិតកម្មកៅស៊ូ កើនពី ៣២.០០០តោន ដល់ ៣៧.០០០តោន ។ ម្យ៉ាងទៀត នៅរវាងឆ្នាំ២០០៧-០៨ ផ្ទៃដីដាំដុះសរុបសំរាប់ដំឡូងឈើ កើនពី ៩៦.០០០ហ.ត ដល់ ១៨០.០០០ហ.ត និងផ្ទៃដីដាំកៅស៊ូ កើនពី ៨២.០០០ហ.ត ដល់ ១០៩.០០០ហ.ត ។ ក្នុងពេលជាមួយគ្នា ផលិតកម្ម និងផ្ទៃដីដាំដុះសំរាប់ដំណាំស្រូវ និងសណ្តែកសៀង ក៏កើនឡើងដែរ (ក្រាហ្វិក ១) ។

ជាការគួរឲ្យស្តាយ វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ច បានរារាំងដល់និន្នាការឡើងថ្លៃនេះ ។ តំរូវការ ពិភពលោកដែលថយចុះ គឺជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀត ដែលធ្វើឲ្យផលិតផលកសិកម្មជាច្រើនប្រភេទ ធ្លាក់ថ្លៃ ទោះបីជាផលិតផលទាំងនោះនៅតែមានថ្លៃខ្ពស់ជាងកំរិតថ្លៃជាមធ្យម កាលពីទស្សវត្សរ៍មុនក្តី ។ តំរូវការពិភពលោកថយចុះ ធ្វើឲ្យផលដែលកសិករប្រមូលបាន មិនសូវមានគេត្រូវការ ហើយពួកគាត់ក៏ទទួលបានផលចំណេញតិច ឬគ្មានផលចំណេញសោះសំរាប់យកទៅសងបំណុល និង សំរាប់ប៉ះប៉ូវលើវិនិយោគរបស់គាត់ ។

នៅចំពោះមុខវិបត្តិនេះ វិស័យកសិកម្មកម្ពុជាមានកំលាំងទ្រាំទ្រមាំទាំល្អ ជាពិសេសបើធៀបនឹង វិស័យដទៃទៀតដែលជំរុញកំណើនសេដ្ឋកិច្ច ។ គេប៉ាន់ប្រមាណថា នៅឆ្នាំ២០០៨ វិស័យកសិកម្ម មានកំណើន ៤,៥% ដែលបានផ្តល់កំលាំងទ្រទ្រង់ដ៏ចាំបាច់ដល់សេដ្ឋកិច្ចកម្ពុជា ។ ទោះយ៉ាងនេះក្តី ការនាំចេញផលិតផលកសិកម្មក៏មានការប៉ះពាល់មួយកំរិតដែរ ។ វិវាទព្រំដែនជាមួយប្រទេសថៃ និងគោលនយោបាយការពារផលិតកម្មក្នុងស្រុកដែលថៃបានដាក់អនុវត្ត ក៏បានរារាំងផងដែរដល់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ។

ក្នុងចំណោមផលិតផលកសិកម្មដែលនាំចេញបានរបស់កម្ពុជា ដំឡូងឈើ និងកៅស៊ូ ទំនងជាទទួលរងការប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយសារមានការធ្លាក់ចុះភ្លាមៗនៃថ្លៃ និងតំរូវការពិភពលោក ។ ថ្វីបើផលិតកម្មសរុបគិតពេញមួយឆ្នាំ២០០៨ បានកើនឡើងក៏ពិតមែន ប៉ុន្តែកំណើនផលិតកម្មដំឡូងឈើ និងកៅស៊ូ បានធ្លាក់ចុះយ៉ាងខ្លាំង នៅត្រីមាសទី៤ ឆ្នាំ២០០៨ បើធៀបនឹងឆ្នាំ២០០៧ ។ គេប៉ាន់ប្រមាណថា នៅចុងឆ្នាំ២០០៨ ដំណាំទាំងពីរនេះ បានធ្លាក់ថ្លៃ ប្រហែល ៥០% បើធៀបនឹងកាលពីមួយឆ្នាំមុន ។ ថ្លៃក្នុងមួយតោននៃដំឡូងឈើនាំចេញ ធ្លាក់ចុះពី ៧០ដុល្លារក្នុងឆ្នាំ២០០៧ ដល់ ៣០ដុល្លារក្នុងឆ្នាំ២០០៨ ហើយ ថ្លៃកៅស៊ូនាំចេញ ធ្លាក់ចុះពី ២.០១៦ដុល្លារក្នុងឆ្នាំ២០០៧ ដល់ ១.០២០ដុល្លារក្នុងឆ្នាំ២០០៨ ។ គេបានប៉ាន់ស្មានថា ដំឡូងឈើនាំចេញបានបាត់តម្លៃអស់ ៩៥លានដុល្លារ ហើយ កៅស៊ូបានបាត់តំលៃអស់ ៣៧លានដុល្លារ ។ ការនាំចេញសណ្តែកសៀង និងពោត ក៏ទទួលរងផលប៉ះពាល់ដែរ ប៉ុន្តែការនាំចេញស្រូវ អាចទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិបានយ៉ាងល្អរហូតមកទល់ពេលនេះ ដោយកំរិតថ្លៃ និងតម្លៃនាំចេញនៃស្រូវ បានកើនឡើងក្នុងឆ្នាំ២០០៨ (សូមពិនិត្យមើល ក្រាហ្វិក ២ និង ៣) ។

កត្តាខាងលើ និងចំណាយខ្ពស់លើធាតុចូលកសិកម្ម បានធ្វើឲ្យកសិករដែលដាំដំឡូងឈើ រងនូវការខាតបង់ ចំណែកកសិករដែលដាំកៅស៊ូ ទទួលបានប្រាក់ចំណេញទាបយ៉ាងខ្លាំង នៅក្នុងឆ្នាំ២០០៨ ។ នៅចុងឆ្នាំ២០០៨ ស្រូវប្រាំង ស្រូវវស្សា ពោត និងសណ្តែកសៀង បន្តផ្តល់ប្រាក់ចំណេញ ប៉ុន្តែប្រាក់ចំណេញដែលទទួលបានពីដំណាំ ៣មុខចុងក្រោយ ក៏មានការធ្លាក់ចុះដែរ ។

## វិបត្តិ និងមធ្យោបាយឆ្ពោះទៅមុខ: ចក្ខុវិស័យ និងទិសដៅគោលនយោបាយនៅពេលអនាគត

វិបត្តិបានជួយបង្ហាញថា វិស័យកសិកម្មមានសក្តានុពលក្នុងការជំរុញកំណើនសេដ្ឋកិច្ច ។ សក្តានុពលនេះ អាចមើលឃើញកាន់តែច្បាស់ យោងតាមកត្តាមួយចំនួន ដូចខាងក្រោម:

- គេជឿជាក់ថា ថ្លៃម្ហូបអាហារធ្លាក់ចុះ តែមួយរយៈពេលប៉ុណ្ណោះ

**ក្រាហ្វិក ២: តំលាតថ្លៃ ឆ្នាំ២០០៧_០៨ (គិតជាដុល្លារ)**




*ប្រភព: ព្រឹត្តិប័ត្រតំលៃរបស់ការិយាល័យទីផ្សារកសិកម្ម (Agricultural Marketing Office—AMO) ឆ្នាំ២០០៧ ដល់ ខែមករា ២០០៩ និងស្ថិតិកសិកម្ម ឆ្នាំ២០០៨ (មិនទាន់ផ្សព្វផ្សាយ) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានបង្ហាញនៅក្នុង សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

**ក្រាហ្វិក ៣: ការប្រែប្រួលតម្លៃនាំចេញ ឆ្នាំ២០០៧_០៨ (គិតជាលានដុល្លារ)**




*ប្រភព: តួលេខប៉ាន់ស្មានរបស់ CDRI ដែលបានបង្ហាញនៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

ពីព្រោះតំរូវការរបស់ប្រទេសចិន ឥណ្ឌា និងបណ្តាប្រទេសនៅមជ្ឈិមបូព៌ា ទំនងជានឹងកើនឡើង ។

- ការធ្លាក់ចុះនៃវិស័យផ្សេងទៀត អាចផ្តល់ការលើកទឹកចិត្តដល់កម្លាំងពលកម្មសំរាប់វិស័យកសិកម្ម ។
- កម្ពុជាមានសក្តានុពលខ្លាំងក្នុងការពង្រីកផ្ទៃដីដាំដុះ ។
- លក្ខណៈអំណោយផលនៃធនធានធម្មជាតិនៅកម្ពុជា និងប្រាក់ឈ្នួលពលកម្មទាបក្នុងផលិតកម្មកសិកម្ម បានធ្វើឲ្យកម្ពុជាមានឧត្តមភាពប្រៀបធៀបក្នុងវិស័យកសិកម្ម ។
- មានការលើកទឹកចិត្តផ្នែកទីផ្សារសំរាប់គាំទ្រដល់ផលិតកម្មកសិកម្ម

(ដូចជា កិច្ចព្រមព្រៀងទ្វេភាគី ជាមួយចិន និង បណ្ដាប្រទេសនៅមជ្ឈិមបូព៌ា និងអាហ្វ្រិក) ។

ដើម្បីសម្រេចឲ្យបានតាមសក្ដានុពលនៃវិស័យកសិកម្ម គេត្រូវអនុវត្តវិធានការមួយចំនួនសំដៅបង្កើនផលិតកម្ម និងផលិតភាព ។ វិធានការទាំងនេះ រួមមាន:

- កំណែទម្រង់ដីធ្លី: គេគួរធ្វើឲ្យប្រសើរឡើងទៀតនូវគោលនយោបាយបែងចែកដីឡើងវិញសំរាប់គ្រួសារអ្នកគ្មានដី ។ រឿងនេះរឹតតែសំខាន់ថែមទៀត តាមការពិនិត្យឃើញជាក់ស្ដែងថា គ្រួសារកាន់កាប់ដីតូចៗ កន្លងមកគឺមានផលិតភាពខ្ពស់ក្នុងការដាំដុះដំណាំជាច្រើនប្រភេទ ។ បញ្ហាសំខាន់ចុងក្រោយគឺ ការចុះបញ្ជីដីធ្លីគួរអនុវត្តឲ្យបានកាន់តែលឿន និងមានប្រសិទ្ធភាព ពីព្រោះយ៉ាងហោចណាស់វាអាចជួយបង្ការករណីទន្ទ្រានយកដី ដែលជាទង្វើមួយគំរាមកំហែងដល់ សន្តិសុខរបស់គ្រួសារកសិករក្រីក្រជាច្រើន ។ ប្រជាពលរដ្ឋ គួរទទួលបានការអប់រំបន្ថែមអំពីសារ:សំខាន់នៃការផ្ទេរកម្មសិទ្ធិដីធ្លីតាមប្រព័ន្ធច្បាប់ ។
- ការប្រើប្រាស់ដី: គេគួរពិនិត្យលទ្ធភាពប្រើប្រាស់ដីសំបូរជីជាតិ ប៉ុន្តែមិនទាន់បានប្រើប្រាស់ ដូចជា ផ្ទៃដីនៅជុំវិញបឹងទន្លេសាបជាដើម ដើម្បីពង្រីកផ្ទៃដីដាំដុះ ។ អាចមានប្រយោជន៍ដូចគ្នាដែរក្នុងការស្វែងរកផ្ទៃដីព្រៃដែលសាកសមយកធ្វើដូចជាចំការកៅស៊ូជាដើម ពីព្រោះវាអាចផ្ដល់តំលៃខាងសេដ្ឋកិច្ច បានច្រើនជាងស្ថានភាពបច្ចុប្បន្ន ។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ: ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងធារាសាស្ត្រ មានសារ:សំខាន់បំផុត ។ តាមមតិរបស់ធនាគារពិភពលោក ការវិនិយោគលើធារាសាស្ត្រ និងការកែលំអផ្លូវជនបទ វាផ្ដល់ផលត្រលប់វិញយ៉ាងច្រើន ។ វាជួយបង្កើនផលិតភាពដំណាំ កាត់បន្ថយចំណាយផលិតកម្ម និងបង្កើនប្រាក់ចំណេញសំរាប់ប្រជាកសិករ ។ ជាឧទាហរណ៍ គេបានប៉ាន់ស្មានថា អនុបាតចំណេញ–ចំណាយនៃវិនិយោគលើធារាសាស្ត្រ (ចំណូលបន្ថែមក្នុងមួយហិកតានៃតំបន់ស្រោចស្រព ចែកនឹង ចំណាយមួយឯកតានៃធារាសាស្ត្រ) មានតួលេខចាប់ពី ១,៥ នៅតំបន់ទន្លេសាប ដល់ ១,៩ នៅតំបន់វាលទំនាប នៅក្នុងឆ្នាំ២០០៤ និងកើនលើសពី ២.០ នៅក្នុងឆ្នាំ២០០៧ ។
- វិនិយោគ និងហិរញ្ញប្បទាន: ការបង្កើតមូលនិធិសាធារណ:សំរាប់វិស័យកសិកម្ម ដែលអាចផ្ដល់ជំនួយហិរញ្ញវត្ថុ ដល់ប្រជាកសិករគឺជាការអភិវឌ្ឍមួយដែលគួរឲ្យត្រេកអរណាស់ ។ ការផ្ដល់កម្ចីបានកាន់តែច្រើន មានអត្រាការប្រាក់កាន់តែទាប និងមានរយ:ពេលសងកាន់តែវែង ក៏អាចជួយសំរាលបន្ទុកបំណុលរបស់ប្រជាកសិករដែលខិតខំតស៊ូផងដែរ ។
- ការពង្រីកការស្រាវជ្រាវ និងអភិវឌ្ឍន៍: ការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ អាចផ្ដល់ផលចំណេញច្រើន ។ ធនាគារពិភពលោក បានកត់សម្គាល់ថា វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យកសិកម្ម (រួមជាមួយនឹងការកែលំអផ្លូវជនបទ) ផ្ដល់ផលត្រលប់បានច្រើនបំផុត សំរាប់ការកាត់បន្ថយភាពក្រីក្រ ។ ឧទាហរណ៍ នៅប្រទេសចិន កំណើន ១% នៃចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យកសិកម្ម វាបង្កើន ផសស នៃវិស័យកសិកម្មក្នុងមនុស្សម្នាក់ បានដល់ ០,០៨៥% ហើយ កំណើននៃ ផសស នេះនឹងកាត់បន្ថយចំនួនប្រជាជនក្រីក្រ នៅចិន បាន ០,១% ។
- ការកែលំអខាងបច្ចេកទេស និងវិទ្យាសាស្ត្រ និងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធាតុចូល: គេត្រូវជំរុញដល់ការផ្សព្វផ្សាយពីបច្ចេកទេសក្សេត្រសាស្ត្រ ការជ្រើសរើសយកពូជផ្ដល់ទិន្នផលខ្ពស់ និងការប្រើប្រាស់ជីឲ្យបានកាន់តែប្រសើរ ។ ការកែលំអការងារគ្រប់គ្រងដី ជារឿងសំខាន់ណាស់ សំរាប់តំបន់វាលទំនាប ពីព្រោះធនាគារពិភពលោកបានរកឃើញថា កង្វះជីជាតិនៃដីនៅតំបន់នោះគឺជាឧបសគ្គដ៏ចំបងដល់ការដាំដុះ ។ ធនាគារពិភពលោកបានកត់សម្គាល់ទៀតថា ការប្រើប្រាស់ជីនៅកម្ពុជា គឺនៅមានកំរិតទាបជាង និងមានប្រសិទ្ធភាពតិចជាងប្រទេសជិតខាង ។ ការដោះស្រាយបញ្ហានេះ នឹងនាំមកនូវផលចំណេញយ៉ាងច្រើន ។ គេបានប៉ាន់ស្មានថា ការបង្កើនការប្រើប្រាស់ជី ១% នឹងបង្កើនទិន្នផលស្រូវ ០,២២% សំរាប់ស្រូវប្រាំង និង ០,២៧% សំរាប់ស្រូវវស្សា ។

ជាបន្ថែមទៅលើវិធានការដូចខាងលើ គេក៏គួរតែជំរុញដល់ការដោះដូរពត៌មាន និងពាណិជ្ជកម្មកសិកម្មផងដែរ ។ ចំរុះកម្មទីផ្សារ និងផលិតផលត្រូវធ្វើឡើងជាចាំបាច់ ។ រដ្ឋាភិបាល គួរខិតខំស្វែងរកកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីជាមួយទីផ្សារថ្មីៗ ។ កម្ពុជា ចាំបាច់ត្រូវពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសចិន ដែលជាអ្នកនាំចូលចំបងគេនូវផលិតផលកសិកម្មសំរាប់ប្រើប្រាស់ក្នុងឧស្សាហកម្មអេតាណុល ។ ស្របពេលជាមួយគ្នានោះ ដើម្បីបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្មកម្ពុជា គេចាំបាច់ត្រូវបន្ថែមវិនិយោគ ទៅលើបច្ចេកវិទ្យាកែច្នៃក្រោយពេលប្រមូលផល ដូចជា ប្រព័ន្ធសំរាប់កិន កែច្នៃ និងស្តុកទុក ជាដើម ។ ប្រជាកសិករកម្ពុជាភាគច្រើន ខ្វះការយល់ដឹងពីថ្លៃទីផ្សារបច្ចុប្បន្ន ដែលនាំឲ្យពួកគាត់ងាយចាញ់បោកគេ ។ ដូច្នេះហើយ ការផ្សព្វផ្សាយអំពីថ្លៃទីផ្សារត្រូវតែកែលំអឡើង ជាពិសេសនៅតំបន់ជនបទ ។ អ្នកដែលចាប់អារម្មណ៍ជំរុញដល់ការអនុវត្តអនុសាសន៍ខាងលើនេះ គួររួមគ្នាជាក្រុមធ្វើការបញ្ចុះបញ្ចូលរួមគ្នា ដល់អ្នកបង្កើតគោលនយោបាយ ទើបទទួលបានប្រសិទ្ធភាពខ្ពស់ ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា គឺជាគំរូមួយស្រាប់ ទាក់ទងនឹងរឿងនេះ ។

នៅកម្ពុជា ភាពក្រីក្រភាគច្រើនកើតមាននៅតំបន់ជនបទ ។ ដោយសារតំបន់ជនបទ ពឹងផ្អែកជាចំបងលើ វិស័យកសិកម្ម ដូច្នេះការដោះស្រាយបញ្ហាដែលរាំងស្ទះដល់ការរីកចំរើនវិស័យកសិកម្ម គឺជារឿងសំខាន់ណាស់ ។ នៅក្នុងដំណាក់កាលនេះ ការអភិវឌ្ឍវិស័យកសិកម្ម គឺជាគន្លឹះសំរាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍ ទៅថ្ងៃអនាគត ។

**CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh, website: http://www.cdri.org.kh